JICA កម្ពុជា

គម្រោងពង្រឹងប្រព័ន្ធអភិវឌ្ឍន៍ធនធានមនុស្សវិស័យសុខាភិបាល

The Project for Strengthening Human Resources Development System of Co-medicals

ព្រឹត្តិបត្តិព័ត៌មានគម្រោង HRD-JICA លេខ ៩ ខែមីនា ឆ្នាំ ២០១១

# មិត្តភាពរវាងប្រទេសកម្ពុជា និង ប្រទេសជប៉ុន និង ការចូលរួមរំលែកទុក្ខជាមួយប្រជាជនជប៉ុន

នៅខេត្តកំពង់ចាម មានស្ពានមួយឈ្មោះថា ស្ពានគីសូណា។ ប្រភពនៃឈ្មោះ KIZUNA បានមកពីភាសាជប៉ុន។ ក្រោយពេលស្ពាននេះបានសាងសង់រួចរាល់ ស្ពាននេះក៏ត្រូវបាន ដាក់ឈ្មោះថា ស្ពានគីសូណា ដើម្បីជានិមិត្តរូប នៃមិត្តភាពកម្ពុជាជប៉ុន។ ចាប់តាំងពីសង្គ្រាមស៊ីវិលក្នុងប្រទេសកម្ពុជាត្រូវបានបញ្ចប់មកទល់ពេលនេះ ប្រទេសជប៉ុនបានផ្តល់ជំនួយអភិវឌ្ឍន៍ជាច្រើនលើគ្រប់វិស័យដល់ប្រទេសកម្ពុជា។ ប៉ុន្តែជាអកុសល កាលពីថ្ងៃទី១១ ខែមីនា ២០១១ ប្រទេសជប៉ុនបានទទួលរងនូវគ្រោះមហន្តរាយធម្មជាតិ រញ្ជួយដី និង រលកយក្ស ស៊ូណាមិ។ ប្រទេសកម្ពុជាបានធ្វើការផ្សព្វផ្សាយពត៌មានពីគ្រោះធម្មជាតិនេះតាំងពីព្រឹករហូតដល់យប់។ រដ្ឋាភិបាលកម្ពុជា ក៏បានចូលរួមជាទឹកប្រាក់ចំនួនដប់ម៉ឺនដុល្លា ដល់រដ្ឋាភិបាលជប៉ុនផងដែរ។ ប្រជាជនកម្ពុជាជាច្រើននាក់បានចូលរួមសរសេរសារក្នុងបញ្ជីរំលែកទុក្ខ និង ចូលរួមឧបត្ថម្ភនៅឯស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា។ ខ្ញុំបានឮថា ក្នុងការចូលរួមឧបត្ថម្ភនេះ ក៏មានអ្នកដែលមានចំណូលទាបជាង ១ដុល្លាក្នុងមួយថ្ងៃដូចជា អ្នកធាក់ស៊ីក្លូ អ្នករត់ម៉ូតូឌុបផងដែរ។ លើសពីនេះទៅទៀត នៅមជ្ឍមណ្ឌលសហប្រតិបត្តិការកម្ពុជាជប៉ុន ក្រុងភ្នំពេញ បាននិមន្តព្រះសង្ឃជាង៥០អង្គ ដើម្បីប្រារព្ធពិធីឧទ្ទិសកុសលដល់ជនរងគ្រោះដោយសារគ្រោះមហន្តរាយនេះ ក្នុងនោះក៏មានការចូលរួមពីប្រជាជនកម្ពុជាជាច្រើននាក់ផងដែរ។ នៅក្នុងគម្រោង HRD-JICA ក៏មានក្រុមគ្រួសារនៃអ្នកជំនាញការម្នាក់ បានទទួលការរងគ្រោះដោយគ្រោះមហន្តរាយនេះ នៅពេលដែលគាត់កំពុងបំពេញការងារនៅប្រទេសកម្ពុជា។ យើងមានអារម្មណ៍ថា ប្រវត្តិសាស្ត្រមិត្តភាពកម្ពុជាជប៉ុន និង ទឹកចិត្តសប្បុរសធមិរបស់ប្រជាជនជប៉ុនមានតំលៃពុំអាចកាត់ថ្លៃបាន។ យើងជឿជាក់យ៉ាងមុតមាំចំពោះចំណងមិត្តភាពរវាងប្រទេសជប៉ុន និងពិភពលោករាប់បញ្ចូលទាំងប្រទេសកម្ពុជានិងប្រទេសដទៃទៀតដែលបានទទួល ជំនួយពីប្រទេសជប៉ុន ។ មកទល់ពេលនេះ ប្រទេសជប៉ុនបានទទួលជំនួយពីប្រទេសដទៃទូទាំងពិភពលោកវិញ។ ដោយសារទំនាក់ទំនង រវាងជប៉ុននិង ពិភពលោកយើង-មានអារម្មណ៍ ថាការជួយជ្រោមជ្រែងនេះបានធ្វើឱ្យប្រជាជនជប៉ុនមានភាពកក់ក្តៅនិងសេចក្តីក្លាហាន អាចប្រឈម មុខនឹងបញ្ហាទាំងនោះបាន។ ប្រជាជនជប៉ុនពិតជាមិនអាចភ្លេចនូវសណ្តានចិត្តនេះឡើយ។ ចំពោះយើងខ្ញុំជាជំនាញការជប៉ុនដែលកំពុងបំពេញការងារក្នុងប្រទេសកម្ពុជា និង មិនទាន់អាចត្រឡប់ទៅប្រទេសជប៉ុនបាននោះ ខ្ញុំគិតថាមានតែការបន់ស្រន់សូមឱ្យជំនះនូវរាល់ឧបសគ្គ ហើយយើងបន្តធ្វើការអភិវឌ្ឍន៍កម្ពុជាដើម្បីរីតចំណងកម្ពុជាជប៉ុន។ យើងសូមបន់ ស្រន់ចំពោះតំបន់រងគ្រោះឱ្យឆាប់ងើបឡើងវិញ និងសូមចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំចំពោះជនរងដោយសារគ្រោះមហន្តរាយនេះ។








រូបខាងលើ : ពិធីឧទ្ទិសកុសលដល់ជនរងគ្រោះនៅប្រទេសជប៉ុន

រូបខាងក្រោម: រូបបោះពុម្ពលើក្រដាសប្រាក់ ៥០០រៀល

## ការបើកសិក្ខាសាលាស្តីអំពីការបង្កើតលិខិតបទដ្ឋានគិលានុបដ្ឋាក

វេជ្ជបណ្ឌិត គិលានុបដ្ឋាក ឆ្មប ឱសថការី អ្នកបច្ចេកទេសមន្ទីរពិសោធន៍ ជាដើម ក្រោយពេលបញ្ចប់ការសិក្សាតាមគ្រឹះស្ថានបណ្តុះបណ្តាលរួច ពួកគេទៅធ្វើការនៅតាមអង្គភាពរដ្ឋ និង ឯកជន។ នៅប្រទេសកម្ពុជា ដើម្បីធានាបាននូវគុណភាពធនធានមនុស្សវិស័យសុខាភិបាលគឺត្រូវធានានូវគុណភាពនៃការបណ្តុះបណ្តាល គុណភាពនៃការប្រកបវិជ្ជាជីវៈ និង ការបង្កើតឱ្យបាននូវប្រព័ន្ធមួយដើម្បី ធានានូវការផ្តល់សេវាដែលមានគុណភាពខ្ពស់។ ប៉ុន្តែដើម្បីសម្រេចបានគោលដៅនេះ ចាំបាច់ត្រូវមានឯកសារគតិយុត្តិជាលាយលក្ខណ៍អក្សរមួយសម្រាប់គ្រប់គ្រងរាល់ការបណ្តុះបណ្តាល និង ការអនុវត្តន៍វិជ្ជាជីវៈ។ ចំពោះគម្រោងគឺសំដៅប្រមូលពត៌មានក្នុងការបង្កើតច្បាប់ដើម្បីធានាឱ្យបាននូវគុណភាពនៃធនធានមនុស្សវិស័យសុខាភិបាលដែលផ្តោតលើផ្នែកឆ្មប និង គិលានុបដ្ឋាក។ រហូតមកទល់ពេល



ការរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល

## ការអង្កេតជាមូលដ្ឋាននៃការបណ្តុះបណ្តាលផ្នែកគិលានុបដ្ឋាក និង ផ្នែកថែទាំនៅតាមមន្ទីរពេទ្យ

ពីថ្ងៃទី១១ ខែកុម្ភៈ រហូតដល់ថ្ងៃទី ១៦ ខែមីនា ក្រុមការងារគម្រោងបានធ្វើការចុះអង្កេតមូលដ្ឋាននៅតាមសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគទាំង៤ និងនៅតាមមន្ទីរពេទ្យជាតិ មន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព។ យើងនឹងធ្វើការបញ្ចូលនូវការរកឃើញនៃការអង្កេតនិងចំណាប់អារម្មណ៍ទៅក្នុងព្រឹត្តិប័ត្រព័ត៌មាននៅ លេខបន្តបន្ទាប់។

ចំពោះក្រុមការងារចុះអង្កេតជាមូលដ្ឋាននេះ មានរូបខ្ញុំផ្ទាល់ Noriko Mochizuki និងអ្នកជំនាញការ១រូបទៀតគឺលោកស្រី Yukie Sakurai លើសពីនេះទៅ ទៀតក៏មានការចូលរួមពីភាគីនៃនាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល គឺលោក ចៅ ស៊ីង លោកផេង វិស្សុត និង លោក ប៊ុន ស្រ៊ីវ។

អ្វីដែលខ្ញុំបានទទួលលើសពីការប្រមែប្រមូលទិន្នន័យគឺ ការឃើញជាក់ស្តែងនូវស្ថានភាពគ្រឹះស្ថានបណ្តុះបណ្តាល និង ហេដ្ឋារចនាសម្ព័ន្ធទាំងឡាយ។ ការមើលត្រឹមតែទិន្នន័យដូចជា តួលេខតែមួយមុខគឺមិនគ្រប់គ្រាន់ឡើយ ។ ដើម្បីទទួលបាននូវចំឡើយ ដ៏ត្រឹមត្រូវមួយជាការលំបាកណាស់។ ប៉ុន្តែយ៉ាងណាក៏ដោយ រូបថតនិងវីដេអូដែលក្រុមយើងបានថតទុកមានសារៈប្រយោជន៍ណាស់ក្នុងការជួយផ្តល់ព័ត៌មានបន្ថែម។

លើសពីនេះទៅទៀត ក្នុងការចុះអង្កេតនៅតាមមន្ទីរពេទ្យ យើងបានសង្កេតឃើញជាក់ស្តែងនូវសកម្មភាពថែទាំអ្នកជម្ងឺដែលផ្តល់ដោយបុគ្គលិកសុខាភិបាល និង ការប្រើប្រាស់ដំណើរការនៃការថែទាំ Nursing Process សំដៅលើកកម្ពស់ គុណភាពនៃការថែទាំនៃវិជ្ជាជីវៈថែទាំនៅតាមមន្ទីរពេទ្យ។ ការធ្វើអង្កេត មូលដ្ឋាននេះ ជាជំហានដំបូងនៃសកម្មភាព គម្រោង។ ដូច្នេះ លទ្ធផលដែលទទួលបាន ត្រូវយកមកប្រើប្រាស់ ជាព័ត៌មានសម្រាប់ សកម្មភាពគម្រោង។



ការប្រជុំជាមួយភាគីគម្រោង

# ការបើកសិក្ខាសាលាស្តីអំពីការបង្កើតលិខិតបទដ្ឋានគិលានុបដ្ឋាក (ត)

នេះ គម្រោងនៅតែបន្តរៀបចំនូវឯកសារទាំងឡាយដូចជា ការប្រមែប្រមូលនូវឯកសារទាំងឡាយដែលមាន ជាពិសេសទាក់ទងទៅនឹង ការងារនៃដៃគូអភិវឌ្ឍន៍ដែលមានពីមុនមក រួមទាំងធ្វើការបកប្រែឯកសារមួយចំនួនដែល ពាក់ព័ន្ធទៀតផង។ លើសពីនេះគម្រោង កំពុងតែធ្វើការរៀបចំនូវឯកសារច្បាប់ដែលទាក់ ទងនឹងការបណ្តុះបណ្តាលនិង ការផ្តល់សេវា ។

កន្លងទៅនេះ អ្នកជំនាញការរយៈពេលខ្លីលោកស្រី Tamura Yayoi ដែលជាអតីតប្រធានការិយាល័យគិលានុបដ្ឋាកនៃក្រសួងសុខាភិបាលប្រទេសជប៉ុន និង ជានាយិកានៃមហាវិទ្យាល័យជាតិថែទាំវេជ្ជសាស្ត្របានអញ្ជើញមកប្រទេសកម្ពុជាដើម្បីបើកសិក្ខាសាលាមួយស្តីពីការបង្កើតគោលការណ៏ច្បាប់គិលានុបដ្ឋាក។ សិក្ខាសាលានេះ បានប្រព្រឹត្តិទៅកាលពីថ្ងៃទី២៨ និង ២៩ ខែមីនានៅក្រសួងសុខាភិបាលក្រោមអធិបតីភាពឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាល ឯកឧត្តមសាស្ត្រាចារ្យ យិត ស៊ុនណារ៉ា អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ទទួលបន្ទុកផ្នែកផ្តល់សេវា និង បណ្តុះបណ្តាលវិស័យសុខាភិបាល លោកស្រី គាត ភួង ប្រធាននាយកដ្ឋានអភិវឌ្ឍន៏ធនធានមនុស្សក្រសួងសុខាភិបាល មន្ត្រីដែលអញ្ជើញមកពីនាយកដ្ឋានបុគ្គលិក នាយកដ្ឋានមន្ទីរពេទ្យ សាលាថែទាំវេជ្ជសាស្ត្រ និង សាលាមធ្យមសិក្សាសុខាភិបាលភូមិភាគទាំង៤ និង ប្រធានផ្នែកថែទាំនៃមន្ទីរពេទ្យជាតិ ដែលសរុបប្រមាណ ជា ៥០ រូប។ ថ្លែងនៅក្នុងសន្ទរកថាបើកពិធីនេះ ឯកឧត្តមសាស្ត្រាចារ្យ យិត ស៊ុនណារ៉ា ក៏ដូចជាប្រជាជនកម្ពុជាទាំងអស់ សូមសំដែងនូវទុក្ខក្រៀមក្រំចំពោះជនរងគ្រោះនៃតំបន់ភាគឦសានប្រទេសជប៉ុន និង សូមថ្លែងអំណរគុណចំពោះភាគីជប៉ុនដែលនៅតែបន្តនូវកិច្ចសហប្រតិបត្តិការជាមួយភាគីកម្ពុជា។



នេះជាលើកទី១ ដែលផ្នែកបណ្តុះបណ្តាលវិស័យសុខាភិបាល និង ផ្នែកផ្តល់សេវា បានធ្វើការផ្លាស់ប្តូរយោបល់ទៅវិញទៅមក។ អ្នកចូលរួមក៏បានលើកឡើងអំពីគម្លាតនៃការបណ្តុះបណ្តាល និង ការផ្តល់សេវា និង ការកែសម្រួលកម្មវិធីសិក្សាបើអាចទៅរួច ទៅតាមតម្រូវការរបស់ខាងផ្នែកផ្តល់សេវា។ មតិរបស់លោកស្រីវេជ្ជបណ្ឌិត Tamura និង មតិរបស់អ្នកចូលរួមត្រូវបានធ្វើការកត់ត្រា និង យកមកពិចារណាក្នុងការបង្កើតគោលការណ៏ច្បាប់គិលានុបដ្ឋាក ក៏ដូចជាសម្រាប់ការបង្កើតគណៈកម្មការអភិវឌ្ឍន៍លិខិតគតិយុត្តិសម្រាប់វិជ្ជាជីវៈគិលានុបដ្ឋាក លេខាធិការដ្ឋាន និង ក្រុមការងារបច្ចេកទេសផងដែរ។




ឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ បានជំរុញឱ្យអង្គពិធីយកចិត្ត ទុកដាក់ទៅលើគោលការណ៏ច្បាប់នៃអាស៊ាន ក៏ដូចជាគោលការណ៏ច្បាប់របស់ប្រទេសជប៉ុន ថាតើយើងគួរបង្កើតឱ្យមានប្រព័ន្ធយ៉ាងដូចម្តេចដែលសាកសមនឹងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្ន។ ដូច្នេះយើងបានបង្កើតជាក្រុមការងារបច្ចេកទេសមួយនៅប្រទេសជប៉ុនសម្រាប់ធ្វើការជួយផ្តល់យោបល់ដល់គណៈកម្មការបង្កើតច្បាប់សម្រាប់វិជ្ជាជីវៈគិលានុបដ្ឋាកនៅកម្ពុជា។

